

# មេភូមិ

Alyson Curro

Nan Hom Noon

Let's Read

The Asia Foundation




ថាគី សុបិនចង់បើកហាងលក់អីវ៉ាន់ដ៏ធំមួយ។
នាងស្រមៃថា ហាងនោះនឹងមានជួរដាក់ធ្នើរដែលពេញដោយ
ចំណីអាហារ ភេសជ្ជៈ និងនំផ្អែមៗ ដែលនាងធ្លាប់ឮពីមុនមក។
នេះជាសុបិនរបស់នាង ពីព្រោះថា តាំងតែពីមានជម្លោះ
ប៉ុន្មានឆ្នាំមក ក្នុងភូមិកាយ៉ាមិនមានអ្វីច្រើនលក់ទេ សូម្បីតែ
ម្ហូបអាហារ។



ថាគី មិនបានបើកហាងលក់អីវ៉ាន់នោះទេ តែនាងបានរកវិធី
ផ្សេងទៀតដើម្បីជួយភូមិរបស់នាង។
នាងចំណាយពេលច្រើនឆ្នាំ ដើម្បីជួយស្ត្រី និងកុមារ និងជួយ
ដោះស្រាយជម្លោះគ្រួសារក្នុងភូមិ។



មានថ្ងៃមួយដែលអ្នកភូមិត្រូវបោះឆ្នោតរើសមេភូមិ។ ទូទាំងភូមិសុទ្ធតែចង់ឱ្យ ថាគី ក្លាយជាអ្នកដឹកនាំរបស់ពួកគេ។ ថាគីពិតជាភ្ញាក់ផ្អើលខ្លាំងណាស់។

មុនដំបូង នាងបានប្រកែក ដោយនាងមានកូនចំនួន៦នាក់ដែលកំពុងរៀន ហើយការងារជាមេភូមិមិនអាចរកចំណូលបានច្រើនឡើយ។ ប៉ុន្តែ អ្នកភូមិពិតជាចង់ឱ្យនាងធ្វើជាមេភូមិរបស់ពួកគេណាស់។ ពួកគេជឿជាក់លើនាងជាខ្លាំង។

ថាគី មានអារម្មណ៍ថា នេះជាតួនាទីរបស់គេ ដូច្នេះនាងក៏

សម្រេចចិត្តធ្វើជាមេភូមិនោះ នៅអាយុ៤៥ឆ្នាំ។



ថាគី បានធ្វើរឿងធំពីរក្នុងអំឡុងពេលដែលនាងធ្វើជាមេភូមិ។
ទីមួយ នាងបានស្តាប់ពីបញ្ហារបស់អ្នកភូមិ ហើយនាងក៏បានរកដំណោះស្រាយចំពោះបញ្ហាទាំងនោះ។
ទីពីរ នាងបានតំណាងភូមិរបស់នាង ក្នុងការប្រជុំសំខាន់ៗជាមួយរដ្ឋាភិបាល។
នាងបានប្រាប់រដ្ឋាភិបាលថា ភូមិរបស់នាងត្រូវការ ផ្លូវល្អជាងនេះ ផ្សារ និងទីកន្លែងថាគី បានធ្វើរឿងធំពីរក្នុងអំឡុងពេលដែលនាងធ្វើជាមេភូមិ។
ទីមួយ នាងបានស្តាប់ពីបញ្ហារបស់អ្នកភូមិ ហើយនាងក៏បានរកដំណោះស្រាយចំពោះបញ្ហាទាំងនោះ។

ទីពីរ នាងបានតំណាងភូមិរបស់នាង ក្នុងការប្រជុំសំខាន់ៗ ជាមួយរដ្ឋាភិបាល។

នាងបានប្រាប់រដ្ឋាភិបាលថា ភូមិរបស់នាងត្រូវការ ផ្លូវល្អជាងនេះ ផ្សារ និងទីកម្សាន្តសាធារណៈសម្រាប់យុវជន។



ថាគី គឺជាមេភូមិស្ត្រីតែមួយគត់ទូទាំង រដ្ឋកាយ៉ា។
តាមការពិតទៅ នាងគឺជាស្ត្រីមួយរូប ក្នុងចំណោម ស្ត្រី
មីយ៉ាន់ម៉ាតែប៉ុន្មានរូបប៉ុណ្ណោះ ដែលបានកាន់តំណែងជាមេភូមិ
និងអ្នកដឹកនាំ។
អ្វីដែលដំណឹងល្អនោះគឺ មានស្ត្រីកាន់តែច្រើនទៅៗបានចូលរួម
និងបង្ហាញថា ពួកគេក៏អាចជាអ្នកដឹកនាំដ៏ល្អបានដែរ។
«នេះមិនមែនជាការងាររបស់តែបុរសនោះទេ។ ស្ត្រីក៏អាច
ធ្វើការងារនេះបានល្អដូចគ្នាដែរ។» ថាគី តែងតែនិយាយថា៖ «ខ្ញុំ
គឺជា តឹកតាងស្រាប់!»



សូមប្រើសាច់រឿងនេះ ដើម្បីសរសេររឿងរបស់ប្អូនមួយលើក្រដាស។

តើពេលណាប្អូនសប្បាយចិត្តជាងគេ?
តើប្អូនចូលចិត្តធ្វើអ្វី?
ពេលខ្លះ ជីវិតពិតជាពិបាក។

សូមរៀបរាប់ពីពេលវេលាពិបាក ដែលប្អូនឆ្លងផុត ក្នុងជីវិត។
សូមនិយាយរឿងមួយនៅពេលអនាគត។
តើប្អូនចង់ធ្វើអ្វី?



សូមគូររូបរបស់ប្អូន។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*The Village Leader*, Author: Alyson Curro. Illustrator: Nan Hom Noon. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by/4.0/
Contributing translators: Somey Chheang